**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

------------

## សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ: ៣៨៣៦ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤
សាលក្រមលេខ:១០៣៧ “ទ” ភ.ព.ព្រ.ទ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥
កំបាំងមុខពិរុទ្ធជន
កំបាំងមុខដើមបណ្តឹង

## ក្នុងនាមប្រជារាស្ត្រខ្មែរ

(សាលក្រមចម្លង)

សាលាដំបូងរាជធានីភ្នំពេញ បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ដោយមានសមាសភាពជំនុំជម្រះដូចខាងក្រោម ៖

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ
លោកស្រី[redacted] តំណាងអយ្យការអម សាលាដំបូងរាជធានីភ្នំពេញ
លោក [redacted] ក្រឡាបញ្ជី សាលាដំបូងរាជធានីភ្នំពេញ
លោក [redacted]ណារ៉ាន មេធាវីការពារក្តីឲ្យជនត្រូវចោទឈ្មោះ[redacted]ធើត, [redacted] ឈុន[redacted] សំអុល, [redacted] វិជ្ជា និង [redacted]វៃ
លោក [redacted]សត្យា និង [redacted]ពិសិដ្ឋ ជាមេធាវីការពារក្តីឲ្យជនត្រូវចោទឈ្មោះ[redacted]សាវៃ [redacted] វិជ្ជា

១.ដើម្បីជំនុំជម្រះ លើអង្គហេតុ **មនុស្សឃាតដោយអចេតនា** តាមមាត្រា២០៧ នៃក្រមព្រហ្មទណ្ឌ។ អង្គហេតុនេះ លោកព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ ចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរ លេខ:៤២០ អ.យ.ផ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥ និងពីចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះតាមដីកាលេខ: ៨៩៧ ដ.ជ.រ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥។ អង្គហេតុ នេះមានជនជាប់ចោទឈ្មោះ[redacted]ឈុន ហៅ មុំ,[redacted] ធើត,[redacted] សំអុល,[redacted] វិជ្ជា និង [redacted]វៃ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រស្មី មានសាវតារជាតិដូចខាងក្រោម៖

១.១ ជនជាប់ចោទឈ្មោះ[redacted] ឈុន ហៅ មុំ ភេទប្រុស អាយុ២១ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើតនៅភូមិ៧៧ ស្រុកចំការលើ ខេត្តកំពង់ចាម និងទីលំនៅបច្ចុប្បន្ននៅការដ្ឋានសំណង់ស្ពានអូ[redacted] ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រ)

ម្តាយឈ្មោះ [redacted](រ) និងប្រពន្ធឈ្មោះ [redacted]គ្មានកូន (ឃុំខ្លួន លេខ២២១៣ ត.ព្រ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៤) ដីកាបង្គាប់ឲ្យដោះលែង លេខ៤២២៥ ត.ព្រ ចុះថ្ងៃទី២៥ ធ្នូ ឆ្នាំ២០១៤[1]។

១.២ ជនជាប់ចោទឈ្មោះ [redacted] ឆើត ភេទប្រុស អាយុ២៣ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើតនៅភូមិព្រីក ស្រុកចំការលើ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅការដ្ឋានសំណង់ស្អាតអូឡាំពិក ផ្លូវ [redacted] ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) និងប្រពន្ធឈ្មោះ [redacted] មានកូន ១នាក់ (ឃុំខ្លួន លេខ២២១០ ត.ព្រ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៤) ដីកាបង្គាប់ឲ្យដោះលែង លេខ៤២២៩ ត.ព្រ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៤។

១.៣ ជនាជាប់ចោទឈ្មោះ [redacted] សំអុល ហៅ ម៉ៅ ភេទប្រុស អាយុ៣៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើតនៅភូមិរកាកូនសត្វ ឃុំបឹងដោរ ស្រុកព្រះស្តេច ខេត្តព្រៃវែង និងទីលំនៅបច្ចុប្បន្ននៅផ្លូវ [redacted] ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) និងប្រពន្ធឈ្មោះ [redacted] មានកូន ១នាក់(ឃុំខ្លួន ២២១២ ត.ព្រ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៤) ដីកាបង្គាប់ឲ្យដោះលែង លេខ៤២២៧ ត.ព្រ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៤។

១.៤ ជនជាប់ចោទឈ្មោះ [redacted] វិជ្ជា ភេទប្រុស អាយុ២០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើតនៅភូមិឈូកស ឃុំឈើទាល ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅការដ្ឋានសំណង់ [redacted] ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) (ឃុំខ្លួន លេខ២២១១ ត.ព្រ ចុះថ្ងៃទី០៥ខែវិច្ឆិកា ឆ្នាំ២០១៤) ដីកាបង្គាប់ឲ្យដោះលែង លេខ៤២២៨ តព្រ ខែធ្នូ ឆ្នាំ២០១៤។

១.៥ ជនជាប់ចោទឈ្មោះ [redacted]វៃ ភេទប្រុស អាយុ២៤ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើតនៅភូមិឈូកស ឃុំឈើទាល ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង និងទីលំនៅបច្ចុប្បន្ន នៅការដ្ឋានសំ [redacted] សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) និងប្រពន្ធឈ្មោះ [redacted] មានកូន ១នាក់(ឃុំខ្លួន លេខ២២០៩ ត.ព្រ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៤) ដីកាបង្គាប់ឲ្យដោះលែង លេខ៤២២៦ ត.ព្រ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៤។

១.៦ ដើមបណ្តឹងឈ្មោះ [redacted] រស្មី ភេទប្រុស អាយុ២៤ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅសង្កាត់និរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងទីលំនៅបច្ចុប្បន្ននៅ [redacted] សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

## ២.ប្រវត្តិនីតិវិធី

២.១. តុលាការអានរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ លេខ:៩០/១៤ រ.ប.ក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ដែលបានសន្និដ្ឋាន និងវាយតម្លៃថា ជនសង្ស័យឈ្មោះ [redacted] ឆើត, [redacted] ឈុន, [redacted]វៃ, [redacted] វិជ្ជា និងឈ្មោះ [redacted] សំអុល ពិតជាបានប្រព្រឹត្តអំពើ មនុស្សឃាតដោយអចេតនា (ធ្វេសប្រហែសពេលកំពុងបំពេញការ

[1] ចៅក្រមស៊ើបសួរ ហេង កេសរោ ចេញដីកាបង្គាប់ឲ្យដោះលែង លេខ៤២២៥ ត.ព្រ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៤។

ងារ បណ្ដាលឱ្យដែកប្លុនជ្រុងធ្លាក់ពីលើត្រូវមនុស្សស្លាប់) ដែលមានជនរងគ្រោះឈ្មោះ[redacted]វណ្ណី កាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៤។

២.២. តំណាងអយ្យការ [redacted] បានចេញដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរ លេខ:២៣៥៨ អយដ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៤[2]។ ចៅក្រមស៊ើបសួរ [redacted] បានចេញដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ លេខ:១៣៨៧ ត.ព្រ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥ និងបានចេញដីកាបញ្ជូនព័ត៌មានអំពីការបិទការស៊ើបសួរទៅតំណាងអយ្យការ[redacted] លេខ:១២៤៤ ត.ព្រ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥ បានចុះហត្ថលេខាទទួលនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ និងទៅជនត្រូវចោទឈ្មោះ[redacted]ឈុន ហៅ មុំ,[redacted] ឆើត, [redacted] សំអុល,[redacted]វៃ និងឈ្មោះ [redacted] វិជ្ជា និងទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted] រស្មី លេខ:១២៤៤ ត.ព្រ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥។

២.៣. តំណាងអយ្យការ[redacted]បានចេញដីកាសន្និដ្ឋានស្ថាពរលេខ:៤២០ អ.យ.ដ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥ បានចោទប្រកាន់លើឈ្មោះ[redacted] ឈុន ហៅ មុំ,[redacted]ឆើត, [redacted] សំអុល,[redacted]វៃ និងឈ្មោះ [redacted] វិជ្ជា ពីបទ:មនុស្សឃាតដោយអចេតនា តាមបញ្ញត្តិមាត្រា២០៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា(ឯកសារលេខ:៥៣/៦)។

២.៤ ចៅក្រមស៊ើបសួរ [redacted] បានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ លេខ:៨៩៧ ដ.ជ.រ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ទៅតំណាងអយ្យការ[3] និងបានចេញដីកាបញ្ជូនព័ត៌មានអំពីការសម្រេចបញ្ជូនរឿងទៅជម្រះ ទៅជនត្រូវចោទឈ្មោះ[redacted] ឈុន ហៅ មុំ[redacted] ឆើត, [redacted]សំអុល,[redacted]វៃ និងឈ្មោះ [redacted] វិជ្ជា និងទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] រស្មី លេខ:៣១៧៧ ត.ព្រ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥។

### ៣.នាពេលសវនាការ

៣.១ តុលាការអានចម្លើយជនជាប់ចោទឈ្មោះ [redacted] ឆើត ដែលបានឆ្លើយនៅកំណត់ហេតុស្ដីពីការសួរចម្លើយ របស់ចៅក្រមស៊ើបសួរ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៤ ថា: នៅថ្ងៃកើតហេតុខ្ញុំនឹងកម្មករចំនួន ០៤នាក់ទៀតនៅដោះជន្ទល់ប្លង់សេបេតុងជាន់ទី១២ ពួកខ្ញុំទាំង០៥នាក់ឡើងដោះដែកជន្ទល់នេះនៅម៉ោង០១រសៀល លុះដល់ម៉ោង០៤រសៀលក៏មានកើតហេតុធ្លាក់ដែកជន្ទល់ចុះក្រោមត្រូវអ្នកធ្វើដំណើរតាមផ្លូវបណ្ដាលឱ្យស្លាប់។ ការធ្លាក់ដែកនេះខ្ញុំពុំបានដឹងពីមូលហេតុអ្វីនោះទេ ព្រោះខ្ញុំពុំនៅក្បែរនោះទេគឺនៅចម្ងាយប្រហែល៥ម៉ែត្រពីដែកនោះ។ ខ្ញុំសំណូមពរសុំឱ្យតុលាការដោះលែងខ្ញុំបាទឱ្យទៅផ្ទះវិញ ដើម្បីរកលុយចិញ្ចឹមកូន។

៣.២ តុលាការអានចម្លើយជនជាប់ចោទឈ្មោះ [redacted] វិជ្ជា ដែលបានឆ្លើយនៅកំណត់ហេតុស្ដីពីការសួរចម្លើយជនត្រូវចោទ របស់ចៅក្រមស៊ើបសួរ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៤ ថា: ខ្ញុំបាទជាកម្មករសំណង់ទទួល

[2] តំណាងអយ្យការ[redacted] បានចេញដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរ លេខ:២៣៥៨ អ.យ.ដ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៤ ដែលបានចោទប្រកាន់ឈ្មោះ[redacted] ឈុន ហៅ មុំ[redacted] ឆើត[redacted]សំអុល,[redacted]វៃ និងឈ្មោ[redacted] វិជ្ជា ពីបទ:មនុស្សឃាតដោយអចេតនា តាមមាត្រា២០៧ នៃក្រមព្រហ្មទណ្ឌ។

[3] ចៅក្រមស៊ើបសួរ [redacted] បានចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted]ឈុន ហៅ មុំ, [redacted]ឆើត, [redacted] សំអុល, [redacted]វៃ និងឈ្មោះ [redacted] វិជ្ជា ពីបទ:មនុស្សឃាតដោយអចេតនា តាមមាត្រា២០៧ នៃក្រមព្រហ្មទណ្ឌ។

បន្ទុកដោះអន្ទារ និងទុកដាក់អន្ទារនៅកន្លែងដើមវិញ។ នៅថ្ងៃកើតហេតុក្រោយធ្វើការហត់ពួកខ្ញុំមាន [redacted] សំអុល, [redacted]វៃ និងរូបខ្ញុំក៏នាំគ្នាទៅហូបទឹកនៅចម្ងាយប្រហែល៦-៧ម៉ែត្រ ស្រាប់តែឮសម្លេងធ្លាក់ប្រាវ។ ក្រោយមកពួកខ្ញុំទាំងបីនាក់ក៏នាំគ្នាទៅមើលឃើញក្តាពុម្ពធ្លាក់មួយផ្ទាំង បន្តិចក៏ឮថាធ្លាក់ដែកត្រូវមនុស្ស ពួកខ្ញុំក៏ចុះក្រោមមកកន្លែងកើតហេតុស្រាប់តែឃើញមនុស្សស្រីម្នាក់ដេកនៅលើផ្លូវ រួចសន្តិសុខក៏បិទខ្ទាឈប់ឲ្យមើលទៀត។ ខ្ញុំពុំបានដឹងថាមានដែកធ្លាក់មកក្រោមនោះទេ ខ្ញុំសំណូមពរឲ្យចៅក្រមមេត្តាដោះលែងខ្ញុំ ដោយសារខ្ញុំបាទគ្មានចេតនាទេ។

៣.៣ តុលាការអានចម្លើយជនជាប់ចោទឈ្មោះ [redacted]វៃ ដែលបានឆ្លើយនៅកំណត់ហេតុស្តីពីការបង្ហាញខ្លួន របស់ចៅក្រមស៊ើបសួរ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៤ ថា: ក្រោយពីខ្ញុំបាទបានដោះជន្ទល់ដែកពុម្ពរួចហើយ ពួកខ្ញុំមិនបានដោះដែកទម្រក្តាពុម្ពបានវៃដែកគោលបន្ទាប់ជាប់ជាមួយក្តារពុម្ព ហើយក្តារពុម្ពក៏មិនទាន់ដោះព្រោះរៀបដែកជន្ទល់មិនទាន់រួច នៅពេលពួកខ្ញុំរៀបរជន្ទល់រួចហើយទើបទម្លាក់មកជាមួយគ្នា។ ខ្ញុំមិនដឹងរឿងក្តាពុម្ពធ្លាក់ចុះទេ ហើយនៅពេលដែលក្តាពុម្ពធ្លាក់ចុះមកក្រោម ដែកទម្រក្តាពុម្ពបានខ្ទាតធ្លាក់ចុះមកដីត្រូវមនុស្ស។ ខ្ញុំសុំឲ្យតុលាការលើកលែងទោស។

៣.៤ តុលាការអានចម្លើយជនជាប់ចោទឈ្មោះ [redacted] សំអុល ដែលបានឆ្លើយនៅកំណត់ហេតុស្តាប់ចម្លើយ របស់មន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ថា: នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៤ ខ្ញុំបានទៅធ្វើការសំណង់នៅស្តាតអូឡាំពិកដោយមានគ្នាទាំងអស់០៥នាក់ដែលមានឈ្មោះ [redacted] វិជ្ជា, [redacted] ឆើត, [redacted] ឈុន និង[redacted]វៃ។ ពេលចូលធ្វើការមេការរបស់ខ្ញុំបានប្រើពួកខ្ញុំឲ្យដោះពុម្ពចេញពីជាន់ទី១២ ហើយពួកខ្ញុំក៏បានដោះជើងទម្រចេញពីពុម្ពតែមិនទាន់ដោះពុម្ពចេញទេ។ បន្ទាប់ពីដោះដែករួចក៏បាននាំគ្នាទៅផឹកទឹក ពេលពួកខ្ញុំកំពុងតែផឹកក៏បានឮសម្លេងស្រែកមកពីក្រោម ស្រែកថាជួយផង មានដែកធ្លាក់ពីលើចុះមកក្រោម។ ចំពោះដែកដែលធ្លាក់នោះគឺដែកដែលនៅជាប់ពុម្ព ហើយពួកខ្ញុំមិនដឹងដោះធ្វើមិចនោះទេ ចំនែកឯដែកនោះធ្លាក់មកដោយរបៀបណាក៏ពួកខ្ញុំមិនបានដឹងដែរ។

៣.៥ តុលាការអានចម្លើយជនជាប់ចោទឈ្មោះ [redacted] ឈុន ដែលបានឆ្លើយនៅកំណត់ហេតុស្តាប់ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៤ ថា: នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៤ ខ្ញុំបានចូលធ្វើការជាកម្មករសំណង់នៅការដ្ឋានសំណង់ស្តាតអូឡាំពិក ពេលចូលធ្វើការពួកខ្ញុំធ្វើការនៅជាន់ទី១២ មានគ្នា០៥នាក់មានរូបខ្ញុំនិងបងខ្ញុំឈ្មោះ [redacted] ឆើត ហើយ០៣នាក់ទៀតខ្ញុំពុំស្គាល់នោះទេ។ ពួកខ្ញុំធ្វើការរហូតដល់មេការរបស់ខ្ញុំឈ្មោះ [redacted] ចាន់ បានមកដល់ហើយបានប្រើពួកខ្ញុំឲ្យរុះជើងអន្ទានៅជាន់ទី១២ មាន០៦ជួរ ពេលដែលខ្ញុំដោះបានដែកចំនួន០១ដើម នៅជាប់ដែកគោលជាមួយក្តារពួកខ្ញុំដោះមិនបាន ក៏ទុកនៅទីនោះ។ ក្រោយមកមេការរបស់ខ្ញុំបានចេញទៅផ្ទះ ហើយពួកខ្ញុំក៏នាំគ្នាសម្រាកហូបទឹក ពេលដែលពួកខ្ញុំកំពុងហូបទឹកក៏បានឮសម្លេងប្រាវហើយខ្ញុំមើលទៅឃើញក្តារដាច់ ហើយជ្រុះដែកមួយចុះមកក្រោមបន្ទាប់មកខ្ញុំមើលទៅឃើញអ្នកដំណើរម្នាក់បានស្លាប់បាត់ទៅហើយ។

៣.៦ តុលាការអានចម្លើយសាក្សីឈ្មោះ[redacted]ស្មី ដែលបានឆ្លើយនៅកំណត់ហេតុស្តាប់ការបំភ្លឺ របស់មន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ថា: នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៤ នាងខ្ញុំបានចេញពីផ្ទះម្តាយក្មេករបស់នាងខ្ញុំនៅភូមិតាង៉ូវ សង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ ក្នុងគោលបំណងមករកទិញគ្រឿងសង្ហារឹម

នៅម្តុំបឹងត្របែក ដោយជិះម៉ូតូមួយគ្រឿងជាមួយគូដណ្តឹងខ្ញុំជាអ្នកឌុបហើយម្តាយក្មេកនាងខ្ញុំជិះពីក្រោយ ឯរូបនាងខ្ញុំជិះកណ្តាល ប៉ុន្តែទិញមិនបានក៏នាំគ្នាទៅមើលគ្រឿងសង្ហារឹមបន្តទៀតនៅម្តុំផ្សារដេប៉ូ រួចហើយក៏នាំគ្នាត្រឡប់ទៅផ្ទះវិញ លុះពេលជិះមកដល់ចំនុចការដ្ឋានសំណង់ក្នុងស្ពាតអូឡាំពិក ក៏មានសម្លេងដែកធ្លាក់មកក្រោមឮសូរផូស នាងខ្ញុំក្រឡេកទៅក្រោយឃើញត្រូវក្បាលម្តាយនាងខ្ញុំ ហើយគាត់ក៏ធ្លាក់ពីលើម៉ូតូដួលទៅដីធ្លាយខួរស្លាប់ភ្លាមនៅនឹងកន្លែងកើតហេតុ។ ក្នុងការរួមដំណើរនោះគឺមានគ្នា០៥នាក់ ជិះម៉ូតូ០៣គ្រឿង ដោយឡែកប្អូនថ្លៃនាងខ្ញុំជិះម៉ូតូមួយគ្រឿងម៉ាក C125 ឌុបឈ្មោះ[redacted]ភក្ត្រ័។

៣.៧ តុលាការអានចម្លើយសាក្សីឈ្មោះ [redacted]សុក្រ័ នៅកំណត់ហេតុស្តាប់ការបំភ្លឺ របស់មន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ថា: នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៤ នាងខ្ញុំជាមួយបងប្អូនព្រមទាំងម្តាយឈ្មោះ [redacted] វណ្ណី បានជិះម៉ូតូមកផ្សារដេប៉ូគោលបំណងរកទិញសម្ភារៈរៀបអាពាហ៍ពិពាហ៍ តែរកទិញមិនបានក៏បានជិះម៉ូតូត្រឡប់មកផ្ទះវិញដោយជិះម៉ូតូ០២គ្រឿង ខ្ញុំជិះម៉ូតូជាមួយ [redacted] រស្មី ឯម្តាយនាងខ្ញុំជិះម៉ូតូ scoopy ជាមួយប្អូននាងខ្ញុំឈ្មោះ [redacted] វាសនា។ ពេលដែលនាងខ្ញុំជិះតាមផ្លូវដល់ការដ្ឋានសំណង់ស្រាប់តែឮសម្លេងដែកធ្លាក់ពីលើការដ្ឋានសំណង់ត្រូវចំក្បាលម្តាយខ្ញុំបណ្តាឲ្យស្លាប់ភ្លាមមួយរំពេច។

៣.៨ តុលាការអានចម្លើយសាក្សី [redacted] វាសនា ដែលបានឆ្លើយនៅកំណត់ហេតុស្តាប់ចម្លើយ របស់មន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ថា: នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៤ ខ្ញុំបានចេញពីផ្ទះមកជាមួយបងប្អូន និងម្តាយខ្ញុំទៅផ្សារដេប៉ូក្នុងគោលបំណងរកទិញសំភារៈរៀបការតែទិញមិនបានក៏ត្រឡប់មកផ្ទះវិញដោយឌុបម្តាយអង្គុយពីក្រោយ។ ពេលដែលជិះមកដល់ការដ្ឋានសំណង់ស្តាតអូឡាំពិក ស្រាប់តែបានឮសម្លេងដែកធ្លាក់ពីលើការដ្ឋានសំណង់ ស្រាប់តែឃើញម្តាយខ្ញុំធ្លាក់ពីលើម៉ូតូហើយក្បាលរបស់គាត់បានបែកស្លាប់មួយរំពេច។

៣.៩ តុលាការអានចម្លើយសាក្សីឈ្មោះ [redacted] ស៊ីង ដែលបានឆ្លើយនៅកំណត់ហេតុស្តាប់ចម្លើយ របស់មន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៤ ថា: នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៤ ខ្ញុំមិនបានមកបម្រើការងារទេរហូតដល់ម៉ោង ១៦ជាង ស្រាប់តែអ្នកដំណើរខាងគ្រប់គ្រងក្រុមហ៊ុនទូរស័ព្ទហើយនឹកស្មានថាសំណង់មានបញ្ហា ខ្ញុំក៏ទៅការដ្ឋានសំណង់នៅស្តាតមើលពេលខ្ញុំទៅដល់ចូលការិយាល័យមានមនុស្សអ៊ូអរ ហើយមានគេប្រាប់ខ្ញុំថាមានអ្នកដំណើរបានស្លាប់ដោយសារដែកធ្លាក់ពីលើសំណង់។

៣.១០ តុលាការអានចម្លើយសាក្សីឈ្មោ[redacted]ចាន់ ដែលបានឆ្លើយនៅកំណត់ហេតុស្តាប់ចម្លើយ របស់មន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៤ ថា: នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៤ ខ្ញុំបានជិះម៉ូតូមកធ្វើការនៅការសាងសង់នៅជាន់ទី១២ កន្លែងកើតហេតុ ដោយកន្លែងកើតហេតុមានកម្មករចំនួន ៥នាក់ ឈ្មោះ [redacted] ឆើត, ឈ្មោះ [redacted] ឈុន, ឈ្មោះ [redacted]វៃ, ឈ្មោះ អុល និងឈ្មោះ វិជ្ជា សុទ្ធតែជាប្រុសៗស្នាក់នៅក្នុងការដ្ឋានទាំងអស់ ហើយសុទ្ធជាកម្មករខាងធ្វើពុម្ព។ ពេលនោះខ្ញុំកំពុងធ្វើការរហូតដល់ម៉ោង ៤រសៀល ខ្ញុំក៏បានចេញទៅផ្ទះ ចំណែកកម្មករខាងលើនៅធ្វើការ។ លុះទៅជិតដល់ផ្ទះស្រាប់តែឈ្មោះ សាវៃ ទូរស័ព្ទប្រាប់ខ្ញុំថា កន្លែងការដ្ឋានសំណង់យើងធ្លាក់ដែកត្រូវអ្នកដំណើរម្នាក់ ខ្ញុំក៏ជិះម៉ូតូត្រឡប់មកវិញ ហើយត្រូវកម្លាំងសមត្ថកិច្ចនាំខ្លួនមកសាកសួរតែម្តង។

៣.១១ តុលាការអានកំណត់ហេតុទទួលវត្ថុតាង លេខ:១០៤២ អ.យ.ង ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៤ (ឯកសារលេខ៤/១) វត្ថុចាប់យកដែលធ្វើការទទួលរួមមាន: ដែកចំនួនមួយដើម បួនជ្រុង ប្រវែងពីរម៉ែត្រពីរតឹក។

៣.១២ តុលាការអាន ពាក្យស្នើសុំដកពាក្យបណ្តឹងរបស់ដើមបណ្តឹង(ឯកសារលេខ៣/១) ដោយមានខ្លឹមសារថា: ខ្ញុំបាទ សូមជម្រាបជូន លោកចៅក្រម មេត្តាជ្រាបថា បន្ទាប់ពីមានករណីគ្រោះថ្នាក់ដែលបណ្តាលឱ្យក្មួយ ក៏ដូចជាប្រពន្ធ និងម្តាយរបស់យើងខ្ញុំបានបាត់បង់ជីវិតរួចមកហើយឃើញថា ភាគីខាងលោក [redacted] Bin ជាតំណាងឱ្យក្រុមហ៊ុន [redacted] បានចូលមកធ្វើការដោះស្រាយសំណងដល់យើងខ្ញុំទាំងអស់គ្នា ក៏ដូចជាបានចូលរួមរំលែកមរណទុក្ខដល់ក្រុមគ្រួសារយើងខ្ញុំដែរ។

៣.១៣ តំណាងអយ្យការសន្និដ្ឋានថា: កាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៤ មានករណីធ្លាក់ដែកនៅការដ្ឋានសំណង់។ តាមការបង្ហាញរបស់ម្ចាស់ការដ្ឋានថាមានកម្មករ ៥នាក់ ជាជនជាប់ចោទ បានធ្វេសប្រហែសបណ្តាលឱ្យស្លាប់ឈ្មោះ [redacted]រស្មី ហើយការធ្វេសប្រហែសនេះបណ្តាលឱ្យស្លាប់មនុស្សជាបទល្មើសមនុស្សឃាតដោយអចេតនាដែលមានចែងតាមមាត្រា២០៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ សុំឱ្យផ្តន្ទាទោសតាមច្បាប់។

៣.១៤ មេធាវី ([redacted]ឈាន) ការពារសិទ្ធិឱ្យជនជាប់ចោទ ([redacted] ឆើត, [redacted] ឈុន, [redacted] សំអុល, [redacted] វិជ្ជា និង[redacted]វៃ) ធ្វើសេចក្តីសន្និដ្ឋានថា: តាមចម្លើយនិងការសន្និដ្ឋានរបស់តំណាងអយ្យការហើយ កូនក្តីខ្ញុំគ្មានចេតនាទេ។ ខ្ញុំសូមឱ្យតុលាការពិចារណាលើការកែពាក្យបណ្តឹងរបស់ដើមបណ្តឹង។ ចំពោះបណ្តឹងអាជ្ញា សុំឱ្យតុលាការពិចារណាសម្រាលទោសឱ្យកូនក្តីខ្ញុំជាកម្មកររកស៊ីចិញ្ចឹមជីវិតដោយសុចរិត មានកម្រិតវប្បធម៌ទាប ជាជនក្រីក្រ ជនជាប់ចោទបានអនុវត្តទោសក្នុងពន្ធនាគារសមល្មមហើយ។ សុំព្យួរទោស តាមមាត្រា១០៧,១០៨ នៃក្រមព្រហ្មទណ្ឌ និងតាមមាត្រា៩៣។

## ៤.សំអាងហេតុ

៤.១ យល់ឃើញថា: ជនជាប់ចោទឈ្មោះ [redacted] ឆើត, [redacted]ឈុន, [redacted]សំអុល, [redacted] វិជ្ជា និង សូ [redacted]វៃ បានឆ្លើយប្រហាក់ប្រហែលគ្នាថា: ពួកគាត់ជាកម្មករសំណង់ទទួលបន្ទុកដោះអន្ទារ និងទុកដាក់អន្ទានៅកន្លែងដើមវិញ។ នៅថ្ងៃកើតហេតុទី០២ ខែវិច្ឆិកា ឆ្នាំ២០១៤ ក្រោយធ្វើការហត់ពួកគាត់បាននាំគ្នាទៅហូបទឹកនៅចម្ងាយប្រហែល៦-៧ម៉ែត្រ ស្រាប់តែឮសម្លេងធ្លាក់ប្រាវ។ ក្រោយមកពួកគាត់ក៏នាំគ្នាទៅមើលឃើញក្តាពុម្ពធ្លាក់មួយផ្ទាំង បន្តិចក៏ឮថាធ្លាក់ដែកត្រូវមនុស្ស ពួកគាត់ក៏ចុះក្រោមមកកន្លែងកើតហេតុស្រាប់តែឃើញមនុស្សស្រីម្នាក់ដេកនៅលើផ្លូវ រួចសន្តិសុខក៏បិទទ្វាឈប់ឱ្យពួកគាត់មើលទៀត។

៤.២ យល់ឃើញថា: ចម្លើយរបស់សាក្សីឈ្មោះ[redacted]ចាន់ បានឆ្លើយថា: នៅថ្ងៃកើតហេតុមានកម្មករចំនួន ៥នាក់ គឺឈ្មោះ[redacted] ឆើត, ឈ្មោះ[redacted] ឈុន, ឈ្មោះ សាវៃ, ឈ្មោះ អុល និងឈ្មោះ វិជ្ជា កំពុងធ្វើការនៅជាន់ទី១២ ហើយកម្មករទាំងនោះសុទ្ធជាកម្មករខាងធ្វើពុម្ព។

៤.៣ យល់ឃើញថា: ចម្លើយរបស់សាក្សីឈ្មោះ[redacted] រស្មី(ឯកសារលេខ:៨/១៨), ចម្លើយសាក្សីឈ្មោះ [redacted]សុភក្រ្ត(ឯកសារលេខ:៧/១៥), ចម្លើយសាក្សីឈ្មោះ[redacted] វាសនា(ឯកសារលេខ៦/១២) បានឆ្លើយប្រហាក់ប្រហែលគ្នាថា: នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៤ ពួកគាត់បានជិះម៉ូតូទៅទិញគ្រឿងសង្ហារឹមដើម្បីរៀបមង្គលការ ប៉ុន្តែទិញមិនបានក៏ជិះត្រឡប់មកផ្ទះវិញ លុះពេលដែលពួកគាត់កំពុងជិះម៉ូតូឆ្លងកាត់ស្ពានអូឡាំពិក ក៏មានដែកធ្លាក់ចុះមកពីលើត្រូវម្តាយគាត់បែកក្បាលស្លាប់នៅកន្លែងកើតហេតុ។

៤.៤ យល់ឃើញថា: តាមមាត្រា២០៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងថា "បទមនុស្សឃាតដោយអចេតនា គឺជាអំពើបណ្តាលឲ្យស្លាប់អ្នកដទៃដោយ:១.ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា ២.ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ។ បទមនុស្សឃាតដោយអចេតនាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២.០០០.០០០(ពីរលាន)រៀល ទៅ៦.០០០.០០០(ប្រាំមួយលាន)រៀល។

៤.៥ យល់ឃើញថា: វត្ថុចាប់យកនៅក្នុងកំណត់ហេតុទទួលវត្ថុតាង លេខ:១០៤២ អ.យ.ដ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៤ (ឯកសារលេខ៤/១) មាន: ដែកចំនួនមួយដើម ឬទដ្រុង ប្រវែងពីរម៉ែត្រពីរតឹក វត្ថុនេះគ្មានតម្លៃនៅក្នុងទីផ្សារទេ ដូចនេះតុលាការគប្បីសម្រេចរឹបអូសបំផ្លាញចោល។

៤.៦ យល់ឃើញថា: ក្រោយពីបានពិនិត្យចម្លើយជនជាប់ចោទទាំងបីដំណាក់កាល ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌, ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ ជនជាប់ចោទឈ្មោះ [redacted] ឆើត, [redacted], [redacted] សំអុល, [redacted] វិជ្ជា និង [redacted]វៃ មិនបានតវ៉ាថា ខ្លួនមានវិប្បល្លាសស្មារតីទេ។ ដូច្នេះតុលាការអាចវាយតម្លៃបានថា គ្មានហេតុផលណាមករារាំងដែលនាំឲ្យតុលាការមិនអាចចេញសេចក្តីសម្រេចផ្តន្ទាទោសលើជនជាប់ចោទទាំងបីខាងលើឡើយ។

៤.៧ ប្រវត្តិសកម្មភាពរបស់ជនជាប់ចោទឈ្មោះ[redacted] វិជ្ជា យោងលើកកំណត់ហេតុស្តីពីការសួរចម្លើយ (ឯកសារលេខ:២១/២) ជនជាប់ចោទឈ្មោះ[redacted]វិជ្ជា មុនកំឡុងពេលកើតហេតុគាត់ធ្វើអំពើល្អក្នុងសង្គម និងមិនធ្លាប់ត្រូវបានតុលាការសម្រេចផ្តន្ទាទោសទេ។ គាត់មានមុខរបរជាកម្មករសំណង់ ដូច្នេះតុលាការគប្បីគិតដល់ស្ថានសម្រាលទោស។

៤.៨ ប្រវត្តិសកម្មភាពរបស់ជនជាប់ចោទឈ្មោះ[redacted] ឆើត យោងលើកកំណត់ហេតុស្តាប់សួរចម្លើយ (ឯកសារលេខ:៩/២១) ជនជាប់ចោទឈ្មោះ [redacted] ឆើត មុនកំឡុងពេលកើតហេតុគាត់ធ្វើអំពើល្អក្នុងសង្គម និងមិនធ្លាប់ត្រូវបានតុលាការសម្រេចផ្តន្ទាទោសទេ។ គាត់មានមុខរបរជាកម្មករសំណង់ ដូច្នេះតុលាការគប្បីគិតដល់ស្ថានសម្រាលទោស។

៤.៩ ប្រវត្តិសកម្មភាពរបស់ជនជាប់ចោទឈ្មោះ[redacted] សំអុល យោងលើកកំណត់ហេតុស្តាប់សួរចម្លើយ (ឯកសារលេខ:១៤/៣៦) ជនជាប់ចោទឈ្មោះ[redacted] សំអុល មុនកំឡុងពេលកើតហេតុគាត់ធ្វើអំពើល្អក្នុងសង្គម និងមិនធ្លាប់ត្រូវបានតុលាការសម្រេចផ្តន្ទាទោសទេ។ គាត់មានមុខរបរជាកម្មករសំណង់ ដូច្នេះតុលាការគប្បីគិតដល់ស្ថានសម្រាលទោស។

៤.១០ ប្រវត្តិសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted]វៃ យោងលើកកំណត់ហេតុស្តាប់សួរចម្លើយ (ឯកសារលេខ:២៣/៣៣) ជនជាប់ចោទឈ្មោះ [redacted]វៃ មុនកំឡុងពេលកើតហេតុគាត់ធ្វើអំពើល្អក្នុងសង្គម និងមិនធ្លាប់ត្រូវបានតុលាការសម្រេចផ្តន្ទាទោសទេ។ គាត់មានមុខរបរជាកម្មករសំណង់ ដូច្នេះតុលាការគប្បីគិតដល់ស្ថានសម្រាលទោស។

៤.១១ ប្រវត្តិសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ឈុន យោងលើកកំណត់ហេតុស្តាប់សួរចម្លើយ (ឯកសារលេខ:៩/២១) ជនជាប់ចោទឈ្មោះ [redacted] ឈុន មុនកំឡុងពេលកើតហេតុគាត់ធ្វើអំពើល្អក្នុងសង្គម និងមិនធ្លាប់ត្រូវបានតុលាការសម្រេចផ្តន្ទាទោសទេ។ គាត់មានមុខរបរជាកម្មករសំណង់ ដូច្នេះតុលាការគប្បីគិតដល់ស្ថានសម្រាលទោស។

៤.១២ យល់ឃើញថា: ដើមបណ្តឹងបានស្នើសុំដកពាក្យបណ្តឹង (ឯកសារលេខ៣/១) ដោយមានខ្លឹមសារថា: គាត់ សូមជម្រាបជូន លោកចៅក្រម មេត្តាជ្រាបថា ភាគីខាងលោក [redacted] Bin ជាតំណាងឲ្យក្រុមហ៊ុន [redacted] បានចូលមកធ្វើការដោះស្រាយសំណងដល់គាត់ហើយ ហេតុដូច្នេះតុលាកាមិនសម្រេចលើការទាមទារសំណងរបស់ដើមបណ្តឹងទៀតឡើយ។

## ៥. សេចក្តីសម្រេច

៥.១ ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **ឈុន ហៅ មុំ**[4], **ឈ្មោះ** [redacted] **ឆើត**[5], **ឈ្មោះ** [redacted] **សំអុល**[6], **ឈ្មោះ** [redacted] **វិជ្ជា**[7], **និងឈ្មោះ** [redacted] **វៃ**[8] ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ០១(មួយ) ឆ្នាំ តែពិរុទ្ធជនបានអនុវត្តទោសក្នុងពន្ធនាគារបាន ១(មួយ)ខែ ២១(ម្ភៃមួយ)ថ្ងៃរួចមកហើយ ទោសសល់ពីនេះព្យួរធម្មតា និងពិន័យជាប្រាក់ក្នុងម្នាក់ៗ ៣.០០០.០០០ (បីលាន)រៀល ចូលជាថវិការរដ្ឋ ពីបទ: មនុស្សឃាតដោយអចេតនា ប្រព្រឹត្តនៅសង្កាត់វាលវង្ស ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៤ តាមមាត្រា២០៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៥.២ វត្ថុចាប់យកលេខ: ១០៤២ អ.យ.ដ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៤ (ឯកសារលេខ៤/១) មាន: ដែកចំនួនមួយដើម បួនជ្រុង ប្រវែងពីរម៉ែត្រពីរតឹក សម្រេចរឹបអូសបំផ្លាញចោលបន្ទាប់ពីសាលក្រមចូលជាស្ថាពរ។

---

[4] ជនជាប់ចោទឈ្មោះ [redacted] ឈុន ហៅ មុំ ភេទប្រុស អាយុ២១ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើតនៅភូមិ៧៧ ស្រុកចំការលើ ខេត្តកំពង់ចាម និងទីលំនៅ [redacted] សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) និងប្រពន្ធឈ្មោះ [redacted](រ) មានកូន ១នាក់។

[5] ជនជាប់ចោទឈ្មោះ [redacted] ឆើត ភេទប្រុស អាយុ២៣ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើតនៅភូមិព្រីក ស្រុកចំការលើ ខេត្តកំពងចាម ទីលំនៅប [redacted] ក្រុមទី១៦ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) និងប្រពន្ធឈ្មោះ [redacted] មានកូន ១នាក់។

[6] ជនាជាប់ចោទឈ្មោះ [redacted] សំអុល ហៅ ម៉ៅ ភេទប្រុស រាយុ៣៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើតនៅភូមិរកាកូនសត្វ ឃុំបឹងដោរ ស្រុកព្រះស្តេច ខេត្តព្រៃវែង និងទីលំ [redacted] ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) និងប្រពន្ធឈ្មោះ [redacted]ថា មានកូន ១នាក់។

[7] ជនជាប់ចោទឈ្មោ [redacted] វិជ្ជា ភេទប្រុស អាយុ២០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើតនៅភូមិឈូកស ឃុំឈើទាល ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ទីលំនៅប [redacted] ផ្លូវលេខ១៨២ ក្រុម៦២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) ។

[8] ជនជាប់ចោទឈ្មោះ [redacted] វៃ ភេទប្រុស អាយុ២៤ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើតនៅភូមិឈូកស ឃុំទាលស្វាយ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង [redacted] សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) និងប្រពន្ធឈ្មោះ [redacted] មានកូន ១នាក់

៥.៣ ពិរុទ្ធជនឈ្មោះ [redacted] ឆើត, [redacted] ឈុន, [redacted] សំអុល, [redacted] វិជ្ជា និង [redacted] វៃ មានសិទ្ធិទាស់ និង ប្ដឹងឧទ្ធរណ៍ តាមច្បាប់ស្ដីពីវិសោធនកម្ម តាមមាត្រា៣៦៨ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៥.៤ ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] រស្មី មានសិទ្ធិទាស់ និងប្ដឹងឧទ្ធរណ៍ តាមច្បាប់ស្ដីពីវិសោធនកម្ម តាមមាត្រា៣៦៨ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សំណុំរឿងព្រហ្មទណ្ឌលេខៈ ៣៨៣៦ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ត្រូវបានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ និងប្រកាសជាសាធារណៈតាមសាល់ក្រមលេខៈ១០៣៧“ទ” ភ.ព.ព្រ.ទ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ស្របតាមមាត្រា៣៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា

[redacted]

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា

[redacted]

(បានចម្លងត្រឹមត្រូវតាមច្បាប់ដើម)

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥

**ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]